ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ផ្សារមូលបត្រកម្ពុជា
CSX
ក្រុមហ៊ុន ផ្សារមូលបត្រកម្ពុជា
លេខ: ០៩១/២០

ថ្ងៃច័ន្ទ ៤កើត ខែ ជេស្ឋ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ២០២០

# សេចក្តីជូនដំណឹង
## ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធជាផ្លូវការ
## របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

នាព្រឹកថ្ងៃច័ន្ទ ៤កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ ធនាគារ អេស៊ីលីដា ភីអិលស៊ី និងផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) បានប្រារព្ធពិធីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ធនាគារ អេស៊ីលីដា ជាធនាគារពាណិជ្ជទី១ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលចុះបញ្ជីបោះផ្សាយលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក. ដែលមាននិមិត្តសញ្ញា "ធអក" ភាគហ៊ុនចុះបញ្ជីសរុបចំនួន ៤៣៣.១៦៣.០១៩ ភាគហ៊ុន ជាមួយនឹងថ្លៃលក់មូលបត្រលើកដំបូងក្នុងមួយឯកតាស្មើនឹង ១៦.២០០ រៀល និងមានមូលធនូបនីយកម្មទីផ្សារសរុបចំនួន ៧ ទ្រីលានរៀល (ប្រមាណ ១,៧៥ ប៊ីលានដុល្លារអាមេរិក)។

នៅក្នុងពិធីនេះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានគូសបញ្ជាក់ថា នាថ្ងៃនេះការចុះបញ្ជីរបស់ធនាគារ អេស៊ីលីដា នឹងក្លាយជាគម្រូមួយសម្រាប់ជម្រុញដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុផ្សេងទៀតដែលមានបំណង ឬនៅមានភាពស្ទាក់ស្ទើរនៅឡើយ ក្នុងការប្រមូលទុនពីទីផ្សារមូលបត្រ ឱ្យកាន់តែមានភាពជឿជាក់ក្នុងការចាប់យកឱកាសកៀរគរទុនសម្រាប់ពង្រឹងនិងពង្រីកអាជីវកម្មរបស់ខ្លួន។ ក្នុងន័យនេះ ផ្សារមូលបត្រកម្ពុជាបាននឹងកំពុងក្លាយជាច្រកហិរញ្ញប្បទានមួយសម្រាប់ក្រុមហ៊ុននិងសហគ្រាសដែលត្រូវការទុន ជួយគាំទ្រដល់ការរីកចម្រើននៃវិស័យឯកជន និងក៏កំពុងបានផ្តល់នូវបរិយាកាសអំណោយផលដល់អ្នកចូលរួមទីផ្សារទាំងឡាយផងដែរ។ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនិងអនុវត្តនូវគោលនយោបាយយុទ្ធសាស្ត្រនិងវិធានការកែទម្រង់ដ៏មុតស្រួចជាច្រើន សំដៅធានាសម្រេចបាននូវការអភិវឌ្ឍន៍ទាំងសេដ្ឋកិច្ចនិងសង្គមប្រកបដោយចិរភាពនិងបរិយាប័ន។ ជាក់ស្តែងក្នុងរយៈពេលជាង២ទសវត្សរ៍ចុងក្រោយនេះជាមួយនិងសុខសន្តិភាព ស្ថេរភាពនយោបាយ និងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចអនុគ្រោះ ប្រទេសជាតិយើងសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ប្រមាណ ៧,៧%ជាមធ្យមក្នុងមួយឆ្នាំ ហើយនៅឆ្នាំ២០១៦ កម្ពុជាត្រូវបានប្រសិទ្ធនាមថាជាប្រទេសខ្លាសេដ្ឋកិច្ចថ្មីនៅអាស៊ី។ ជាមួយគ្នា

នេះ **លោកជំទាវ នាង ច័ន្ទថាណា** ទេសាភិបាលរងនៃធនាគារជាតិនៃកម្ពុជា បានលើកឡើងថាការបោះផ្សាយលក់មូលបត្រសិទ្ធិរបស់ធនាគារ អេស៊ីដា គឺជាផ្នែកមួយនៃការធ្វើពិពិធកម្មមូលធនបន្ថែមលើមូលនិធិជាប្រាក់បញ្ញើរបស់អតិថិជន និងការខ្ចីមូលនិធិពីក្រៅប្រទេស ហើយក៏ជាជម្រើសផលិតផលហិរញ្ញវត្ថុមួយបន្ថែមទៀតសម្រាប់វិនិយោគិនសក្តានុពលផងដែរ។ ស្របពេលដែលធនាគារអេស៊ីដាទទួលបានទំនុកចិត្តខ្ពស់ ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិនេះ គឺជាផ្នែកមួយនៃការបង្កើនជំនឿទុកចិត្តរបស់ សាធារណជនមួយកម្រិតបន្ថែមទៀត និងជាការ ជម្រុញដល់ដំណើរការទីផ្សារមូលធននៅកម្ពុជាដែលបានអនុវត្តស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥ របស់រាជរដ្ឋាភិបាលកម្ពុជាផងដែរ។ បន្ថែមពីលើនេះ **ឯកឧត្តម ហុង សុហួរ** អគ្គនាយក នៃផ.ម.ក. ក៏បានលើកឡើងផងដែរថា គិតត្រឹមថ្ងៃចុះបញ្ជីនេះ ផ.ម.ក.មានក្រុមហ៊ុនចុះបញ្ជីសរុបចំនួន **១២ក្រុមហ៊ុន** ដែលបានប្រមូលទុនពីផ្សារមូលបត្រសរុបប្រមាណជាង **២៤០ លានដុល្លារអាមេរិក**។ ស្របជាមួយគ្នានេះ សកម្មភាពទីផ្សារក៏មានការរីកចម្រើនច្រើនជាងមុន ដោយសន្ទស្សន៍ថ្លៃភាគហ៊ុនបានកើនឡើងប្រមាណ ៥៨% និងទំហំជួញដូរប្រចាំថ្ងៃកើនឡើងជាង៥ដងក្នុងឆ្នាំ២០១៩ បើធៀបជាមួយឆ្នាំ២០១៨។ ផ.ម.ក.រំពឹងថា នឹងអាចក្លាយជាឧបករណ៍វិនិយោគដ៏មានសក្តានុពលតាមរយៈការធ្វើពិពិធកម្មផលបត្រវិនិយោគសម្រាប់វិនិយោគិន និងអាចក្លាយជាទីផ្សារមួយដែលជួយកៀរគរទុន ផ្តល់ជម្រើសពិពិធកម្មប្រភពទុនថ្មីមួយទៀតបន្ថែមលើប្រភពទុនដែលមានស្រាប់ និងគាំទ្រដល់ការរីកចម្រើនរបស់ក្រុមហ៊ុនក្នុងស្រុកនានា ជួយបង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ ហើយនឹងជួយជម្រុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ក្នុងពិធីនេះ **លោកបណ្ឌិត អ៊ិន ចាន់នី** បានបង្ហាញពីចំណាប់អារម្មណ៍ដ៏មុតមាំផងដែលថា ការចុះបញ្ជីរបស់ធនាគារ អេស៊ីលីដា គឺជាការបើកទំព័រស័ករាជជាថ្មីនៃប្រវត្តិជោគជ័យជាង**២៧ឆ្នាំ** របស់ធនាគារ អេស៊ីលីដា ដោយមានវិនិយោគិនសាធារណៈចំនួន **២,៤៩៧នាក់** ក្លាយជាភាគហ៊ុនិកថ្មីរបស់ធនាគារ និងអាចចូលរួមជួញដូរភាគហ៊ុននៅលើ ផ.ម.ក.។

**ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង÷
លោក ហៃ លីដេត
ប្រធានស្តីទីនាយកដ្ឋានចុះបញ្ជី និងផ្តល់ព័ត៌មាន
អ៊ីម៉ែល÷ lideth.hay@csx.com.kh